**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ០៩ សរ

# សារាចរ

## ស្តីពី

## ការរៀបចំទិវាជាតិសហគ្រាសធុនមីក្រូ តូច និងមធ្យម លើកទី៣ ឆ្នាំ២០២៦

រាជរដ្ឋាភិបាលកម្ពុជា បានកំណត់ថ្ងៃទី២៧ ខែមិថុនា ជារៀងរាល់ឆ្នាំជាទិវាជាតិសហគ្រាសធុនមីក្រូ តូច និងមធ្យម តាមរយៈអនុក្រឹត្យលេខ១៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៤ ស្តីពីទិវាជាតិសហគ្រាសធុនមីក្រូ តូច និងមធ្យម ដោយស្របតាមសេចក្តីសម្រេចលេខ A/RES/71/279 នៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៧ របស់មហាសន្និបាតអង្គការសហប្រជាជាតិ ក្នុងគោលបំណងដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍដោយចីរភាពឆ្នាំ២០៣០ និងបន្តជំរុញការអភិវឌ្ឍវិស័យសហគ្រាសធុនមីក្រូ តូច និងមធ្យម ដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចជាតិ និងជាកម្លាំងចលករសំខាន់ក្នុងការបង្កើតការងារ លើកកម្ពស់ជីវភាពប្រជាពលរដ្ឋ ពង្រឹងភាពធន់នៃសេដ្ឋកិច្ចនិងជំរុញការប្រកួតប្រជែងរបស់កម្ពុជា ក្នុងបរិបទសេដ្ឋកិច្ចពិភពលោក ដែលកំពុងមានភាពមិនច្បាស់លាស់និងការប្រែប្រួលយ៉ាងឆាប់រហ័ស។ សម្រាប់ឆ្នាំ២០២៦នេះ រាជរដ្ឋាភិបាលសម្រេចរៀបចំទិវាជាតិសហគ្រាសធុនមីក្រូ តូច និងមធ្យម លើកទី៣ ក្រោមប្រធានបទ **«សាងស្ពានសម្រាប់សហគ្រាសធុនមីក្រូ តូច និងមធ្យមឆ្ពោះទៅកាន់ទីផ្សារ»** ដែលប្រព្រឹត្តទៅនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៦ ដោយផ្តោតលើគោលបំណងសំខាន់ៗដូចខាងក្រោម៖

១- ផ្សព្វផ្សាយគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីរបស់រាជរដ្ឋាភិបាលក្នុងការគាំទ្រសហគ្រាសធុនមីក្រូ តូច និងមធ្យម និងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដើម្បីលើកកម្ពស់ផលិតភាព គុណភាព ការប្រកួតប្រជែង ជាមួយការត្រៀមខ្លួនរបស់សហគ្រាសធុនមីក្រូ តូច និងមធ្យម សម្រាប់ការចាកចេញរបស់កម្ពុជាពីឋានៈប្រទេសអភិវឌ្ឍតិចតួចនៅចុងឆ្នាំ២០២៩ នាពេលខាងមុខ។

២- បង្កើតវេទិកាតភ្ជាប់រវាងសហគ្រាសធុនមីក្រូ តូច និងមធ្យម ជាមួយទីផ្សារអ្នកផ្គត់ផ្គង់ វិនិយោគិន គ្រឹះស្ថានហិរញ្ញវត្ថុ វេទិកាពាណិជ្ជកម្មឌីជីថល និងសហគ្រាសធំៗ ដើម្បីពង្រឹងខ្សែច្រវាក់តម្លៃនិងជំរុញការផ្គត់ផ្គង់ក្នុងស្រុក។

៣- លើកកម្ពស់ស្មារតីស្នេហាជាតិនិងការគាំទ្រផលិតផលក្នុងស្រុក តាមរយៈការជំរុញឱ្យប្រជាពលរដ្ឋកម្ពុជាងាកមកប្រើប្រាស់ផលិតផលក្នុងស្រុក «ផលិតនៅកម្ពុជា» ដែលមានគុណភាព សុវត្ថិភាព ស្តង់ដា និងការវេចខ្ចប់ប្រកបដោយគុណភាព សោភណភាព និងការទាក់ទាញ។

៤- លើកទឹកចិត្តសហគ្រាសធុនមីក្រូ តូច និងមធ្យម ឱ្យប្រើប្រាស់បច្ចេកវិទ្យាឌីជីថលនិងនវានុវត្តន៍ក្នុងការធ្វើទំនើបកម្មផលិតកម្ម ការគ្រប់គ្រងអាជីវកម្ម និងការធ្វើទីផ្សារ។

៥- ពង្រឹងភាពធន់នៃសហគ្រាសធុនមីក្រូ តូច និងមធ្យម ក្នុងបរិបទភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចពិភពលោក ការប្រកួតប្រជែងតំបន់ និងបញ្ហាប្រឈមផ្នែកភូមិសាស្ត្រនយោបាយនិងពាណិជ្ជកម្មអន្តរជាតិ។

ដើម្បីឱ្យការរៀបចំទិវាជាតិនេះ ប្រព្រឹត្តទៅដោយរលូនប្រកបដោយភាពអធិកអធម រាជរដ្ឋាភិបាល សូមដាក់ចេញនូវវិធានការណែនាំដូចខាងក្រោម៖

១- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ត្រូវទទួលបន្ទុករៀបចំទិវាជាតិនេះនិងត្រូវផលិតជាវីដេអូនិងខ្លឹមសារឯកសារផ្សេងៗដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលរាជធានី ខេត្ត អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍ និងវិស័យឯកជន ដើម្បីធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ នៅទូទាំងប្រទេស។

២- ក្រសួងព័ត៌មានត្រូវណែនាំដល់ប្រព័ន្ធឃោសនារបស់រដ្ឋ ឯកជន និងបណ្ដាញសារព័ត៌មានដូចជា វិទ្យុ ទូរទស្សន៍ កាសែត បណ្ដាញសង្គម និងមធ្យោបាយផ្សព្វផ្សាយផ្សេងទៀតឱ្យធ្វើការផ្សព្វផ្សាយសារាចរ សារលិខិត **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងវីដេអូ ខ្លឹមសារឯកសារផ្សេងៗនៃទិវាជាតិនេះឱ្យបានផុសផុល។

៣- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធនានាត្រូវចូលរួមសហការគាំទ្រ ដើម្បីឱ្យទិវាជាតិសហគ្រាសធុនមីក្រូ តូច និងមធ្យម លើកទី៣ ឆ្នាំ២០២៦ ប្រព្រឹត្តទៅបានដោយរលូន តាមការស្នើសុំសហការរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ទៅតាមលទ្ធភាពរបស់ក្រសួង ស្ថាប័ន។

៤- គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត និងអង្គភាពពាក់ព័ន្ធនានាត្រូវរៀបចំចងបដាពាក្យស្លោក នៅតាមអង្គភាពនិងទីសាធារណៈ តាមខ្លឹមសារដូចខាងក្រោម៖

- អបអរសាទរទិវាជាតិសហគ្រាសធុនមីក្រូ តូច និងមធ្យម លើកទី៣ ឆ្នាំ២០២៦!
- ប្រើប្រាស់ផលិតផលខ្មែរ គឺស្នេហាជាតិ
- ប្រើប្រាស់ផលិតផលខ្មែរ បង្កើតការងារ និងបង្កើនចំណូលសម្រាប់ប្រជាជនខ្មែរ
- មោទនភាពផលិតផលខ្មែរ មោទនភាពជាតិខ្មែរ
- សហគ្រាសធុនមីក្រូ តូច និងមធ្យមមានភាពធន់ សេដ្ឋកិច្ចខ្មែររឹងមាំ ប្រទេសជាតិរុងរឿង
- ផ្គត់ផ្គង់ដោយខ្មែរ ផលិតដោយខ្មែរ វេចខ្ចប់ដោយខ្មែរ រីកចម្រើនសម្រាប់ខ្មែរទាំងអស់គ្នា
- ប្រើប្រាស់ផលិតផលក្នុងស្រុក គាំទ្រសហគ្រាសធុនមីក្រូ តូច និងមធ្យម កម្ពុជា
- សាងស្ពានពីផលិតផលខ្មែរទៅកាន់ទីផ្សារជាតិនិងអន្តរជាតិ
- ហេដ្ឋារចនាសម្ព័ន្ធគុណភាពជាតិជាគន្លឹះនៃភាពរីកចម្រើនរបស់សហគ្រាសធុនមីក្រូ តូច និង មធ្យម កម្ពុជា។

ទទួលបានសារាចរនេះ ទីស្ដីការគណៈរដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត ត្រូវផ្សព្វផ្សាយ និងអនុវត្តឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃពុធ ១០កើត ខែបឋមាសាឍឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ